បណ្ណាគារភក្តីឡប់
PHEAKDEYLAW BOOK STORE

លេខ : ០៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតស្ថានឯកអគ្គរាជទូត
# នៃព្រះរាជាណាចក្រកម្ពុជា
# ប្រចាំសហព័ន្ធម៉ាឡេស៊ី

# ១៩៩៧

ផលិតជាសៀវភៅអេឡិចត្រូនិចដោយបណ្ណាគារភក្តីឡប់

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៧

# អនុក្រឹត្យ

## លេខ ០៤ អនក្រ.បក

## ស្តីពីការបង្កើតស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសហព័ន្ធម៉ាឡេស៊ី

* * *

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការ កែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស.៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម ០១៩៦.១០ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១ :** បង្កើតស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសហព័ន្ធម៉ាឡេស៊ី ដោយមានទីវេសនដ្ឋាន នៅក្រុងកូឡាឡាំពួរ ។

**មាត្រា ២ :** ស្ថានឯកអគ្គរាជទូតនេះ ត្រូវដឹកនាំដោយប្រធានបេសកកម្មទូតម្នាក់ ដែលមានឋានៈជាឯកអគ្គរាជ ទូតវិសាមញ្ញនិងពេញសមត្ថភាព ។

មាត្រា ៣ : សមាសភាពមន្ត្រីការទូតផ្សេងទៀត យ៉ាងច្រើនបំផុតបួននាក់ នឹងត្រូវកំណត់តាមលក្ខការណ៍ការទូត នៃព្រះរាជាណាចក្រកម្ពុជា ។ រីឯបុគ្គលិកមិនមែនការទូតទាំងឡាយនឹងត្រូវកំណត់ដោយរដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

មាត្រា ៤ : មន្ត្រីការទូតតំណាងសេដ្ឋកិច្ច ពាណិជ្ជកម្ម ត្រូវជ្រើសតាំងយកអ្នកមានជំនាញពីមួយនាក់ទៅពីរនាក់ ។

មាត្រា ៥ : អនុព័ន្ធយោធាម្នាក់ ត្រូវជ្រើសតាំងដោយក្រសួងការពារប្រទេស ។

មាត្រា ៦ : ប្រព័ន្ធហិរញ្ញកិច្ចសំរាប់មន្ត្រីនិងបុគ្គលិកនៃស្ថានឯកអគ្គរាជទូតនេះ នឹងស្ថិតក្នុងប្រភេទ « ខ » ។

មាត្រា ៧ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីពាណិជ្ជកម្ម រដ្ឋមន្ត្រីការពារប្រទេស រដ្ឋមន្ត្រីសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការមុខងារសាធារណៈ ត្រូវទទួលបន្ទុករៀងៗខ្លួនអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| **ព្រះហស្តលេខា និង ត្រា** | **ហត្ថលេខា និង ត្រា** |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *